ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ :...៩៧៨...ស.ណ... ប.ស្ក

សូមគោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**កម្មវត្ថុ** ៖ សំណើសុំឱ្យក្រុមហ៊ុនដែលធ្វើកិច្ចសន្យាការពារបរិស្ថាន ត្រូវភ្ជាប់មកជាមួយនូវផែនការគ្រប់គ្រងបរិស្ថាន

**យោង** ៖ - ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តយសសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា ការអនុវត្តកន្លងមកក្រសួងបរិស្ថានបានតម្រូវឱ្យម្ចាស់គម្រោងវិនិយោគមួយចំនួនដូចជារោងចក្រកាត់ដេរ រោងចក្រប៉ាក់សម្លៀកបំពាក់ រោងចក្រស្បែកជើងជាដើម ដែលគម្រោងទាំងនេះមានជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរៀបចំត្រឹមកិច្ចសន្យាការពារបរិស្ថាន គឺមិនបានតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានទេ ដោយសារនៅពេលនោះក្រសួងបរិស្ថានយល់ឃើញថាដើម្បីលើកទឹកចិត្ត និងទាក់ទាញវិនិយោគិនឱ្យចូលមកវិនិយោគក្នុងប្រទេសឱ្យបានកាន់តែច្រើន ជាពិសេស ក្រសួងបរិស្ថានពិនិត្យឃើញថាគម្រោងទាំងនេះមានទំហំផលប៉ះពាល់បរិស្ថានតិចតួចដល់បរិស្ថាន និងសុខភាពកម្មករ។

ដោយឡែក ការអនុវត្តជាក់ស្តែងរបស់រោងចក្រមួយចំនួនបានបង្កឱ្យមានផលប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ រួមមានបង្កឱ្យកម្មករដួលសន្លប់ក្នុងរោងចក្រជាបន្តបន្ទាប់ និងការគ្រប់គ្រងបរិស្ថានក្នុងរោងចក្រមិនបានត្រឹមត្រូវ ជាពិសេសការទុកដាក់វត្ថុធាតុដើមដែលមានសារធាតុគីមី ការគ្រប់គ្រងសំណល់រឹង-រាវ និងអគាររោងចក្រពុំមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់ជាដើម។ ដូចនេះ ដើម្បីបង្ការ ទប់ស្កាត់ កាត់បន្ថយ និងជៀសវាងផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពកម្មករ ក្រសួងបរិស្ថានសម្រេចឱ្យម្ចាស់ក្រុមហ៊ុនដែលធ្វើកិច្ចសន្យាការពារបរិស្ថានសម្រាប់គម្រោងវិនិយោគខាងលើត្រូវភ្ជាប់មកជាមួយនូវផែនការគ្រប់គ្រងបរិស្ថានឱ្យបានច្បាស់លាស់ ដើម្បីឱ្យម្ចាស់ក្រុមហ៊ុនទាំងនេះអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន (សូមភ្ជាប់ជូននូវផែនការគ្រប់គ្រងបរិស្ថាន ០១ច្បាប់)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាចាត់ចែងដោយក្តីអនុគ្រោះ។

សូមឯកឧត្តម មេត្តាទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

សាយ សំអាល់

ចម្លងជូន ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ផែនការគ្រប់គ្រងបរិស្ថាន
## សម្រាប់គម្រោងវិនិយោគបង្កើតរោងចក្រឧស្សាហកម្មធុនស្រាល

**របស់**

**ក្រុមហ៊ុន.....................( ភាសាខ្មែរ )**

...................**( ភាសាអង់គ្លេស )**

រៀបរៀងដោយៈ ............................

ខែ.......... ឆ្នាំ................

២៥៣

# មាតិកា

ទំព័រ

**ជំពូកទី១៖ សេចក្តីផ្តើម**

១.១ ទិដ្ឋភាពទូទៅ..........១

១.២ គោលបំណង..........១

១.៣ វិធីសាស្ត្រសាស្ត្រ..........១

**ជំពូកទី២. ការពិពណ៌នាគម្រោង**

២.១ ប្រវត្តិ និងបទពិសោធន៍របស់ក្រុមហ៊ុន..........១

២.២ ទីតាំងគម្រោង..........១

២.៣ ប្រភេទ/ទំហំគម្រោង និងពេលវេលានៃសកម្មភាពគម្រោង..........១

២.៤ ផែនការសកម្មភាពការងារ..........១

២.៥ កម្មវិធីសកម្មភាពការងាររបស់គម្រោង..........១

**ជំពូកទី៣. ផែនការគ្រប់គ្រងបរិស្ថាន**

៣.១ សង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ..........១

៣.២ កម្មវិធីបណ្តុះបណ្តាល..........១

៣.៣ កម្មវិធីត្រួតពិនិត្យបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង..........១

**ជំពូកទី៤. សន្និដ្ឋាន និងអនុសាសន៍**

## ជំពូកទី១. សេចក្តីផ្តើម

១.១ ទិដ្ឋភាពទូទៅ៖ ត្រូវរៀបចំសង្ខេបពីប្រវត្តិ និងមូលហេតុដែលគម្រោងត្រូវបានបង្កើតឡើង ព្រមទាំងស្ថានភាពទូទៅនៃគម្រោង។

១.២ គោលបំណង នៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាន

១.៣ វិធីសាស្រ្តសាស្រ្ត៖ ត្រង់ចំណុចនេះត្រូវរៀបរាប់អំពីតម្រូវការព័ត៌មាន-ទិន្នន័យ វិធីសាស្រ្តប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ

## ជំពូកទី២. ការពិពណ៌នាគម្រោង

នៅក្នុងជំពូកនេះត្រូវរៀបរាប់ឱ្យបានលម្អិត ដូចមានចែងនៅក្នុងរបាយការណ៍បុរេសិក្សាសមិទ្ធិលទ្ធភាព ឬរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព ឬផែនការមេរបស់ក្រុមហ៊ុន ដែលមានចំណុចមួយចំនួនដូចខាងក្រោម៖

២.១ ប្រវត្តិ និងបទពិសោធន៍របស់ក្រុមហ៊ុន/គម្រោង

២.២ ទីតាំងគម្រោង (ត្រូវភ្ជាប់មកជាមួយនូវផែនទីរដ្ឋបាលតំបន់ និងទីតាំងគម្រោង)

២.៣ ប្រភេទ/ទំហំគម្រោង និងពេលវេលានៃសកម្មភាពគម្រោង (ដំណាក់កាលមុនប្រតិបត្តិគម្រោង ប្រតិបត្តិ បញ្ចប់គម្រោង)

២.៤ ផែនការសកម្មភាពការងារឧទាហរណ៍៖ (១).ប្រភព និងបរិមាណវត្ថុធាតុដើមដែលត្រូវប្រើប្រាស់ (២).តម្រូវការគ្រឿងចក្រ (៣).តម្រូវការកំលាំងពលកម្មក្នុងស្រុក និងក្រៅប្រទេស (៤).បរិមាណផលិតផលសម្រេច (៥).ចំណូល-ចំណាយ (៦).ខ្សែសង្វាក់ផលិតកម្ម (៧).ផែនការគ្រប់គ្រង សំណល់គ្រប់ប្រភេទ។ល។

២.៥ កម្មវិធីសកម្មភាពការងាររបស់គម្រោង

## ជំពូកទី៣. ផែនការគ្រប់គ្រងបរិស្ថាន

នៅក្នុងផ្នែកនេះ ម្ចាស់គម្រោងចាំបាច់ត្រូវមានមូលនិធិគ្រប់គ្រាន់សម្រាប់កិច្ចការពារបរិស្ថាន និងបង្កើតផ្នែក/ក្រុមមួយដែលមានបុគ្គលិកជំនាញប្រកបដោយសមត្ថភាព ឧបករណ៍ វិធីសាស្រ្ត និងកាលវិភាគត្រឹមត្រូវសម្រាប់ត្រួតពិនិត្យគុណភាពបរិស្ថាន ដោយសហការឱ្យបានជិតស្និទ្ធជាមួយក្រសួង/ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានរបស់គម្រោងទៅលើបរិស្ថាន។

ផែនការគ្រប់គ្រងបរិស្ថាននេះ រួមមាន៖

៣.១ សង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

៣.២ កម្មវិធីបណ្តុះបណ្តាល

៣.៣ កម្មវិធីត្រួតពិនិត្យបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោងដែលក្នុងនោះម្ចាស់គម្រោងត្រូវបញ្ជាក់ពី៖

- ស្ថាប័នត្រួតពិនិត្យសម្រាប់ការអង្កេតតាមដានគម្រោង
- កំណត់នូវប៉ារ៉ាម៉ែត្រដែលត្រូវត្រួតពិនិត្យ

- វិធីសាស្ត្រក្នុងការត្រួតពិនិត្យ
- បទដ្ឋានបរិស្ថាន ឬគោលការណ៍ណែនាំណាមួយដែលត្រូវយកមកអនុវត្តក្នុងការត្រួតពិនិត្យ
- កម្មវិធី និងខួបដែលត្រូវត្រួតពិនិត្យ
- ការវាយតម្លៃទៅលើលទ្ធផលនៃការត្រួតពិនិត្យដោយម្ចាស់គម្រោងផ្ទាល់
- ការរៀបចំរបាយការណ៍ប្រចាំត្រីមាស ដើម្បីផ្ញើជូនក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធ

**ជំពូកទី៤. សន្និដ្ឋាន និងអនុសាសន៍**

ក្នុងសេចក្តីសន្និដ្ឋាន ម្ចាស់គម្រោង/ក្រុមហ៊ុន ត្រូវបង្ហាញពីការវិនិយោគដោយលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន បង្ហាញបាននូវនិរន្តរភាពជាវិជ្ជមាននៃបរិស្ថាន និងការលើកកម្ពស់ជីវភាពរបស់សហគមន៍ដែលពាក់ព័ន្ធនៅពេលមានការវិនិយោគកើតឡើងក្នុងតំបន់គម្រោង។

ក្នុងជំពូកនេះ ម្ចាស់គម្រោងត្រូវធានាអះអាង និងទទួលខុសត្រូវលើផែនការគ្រប់គ្រងបរិស្ថាន ព្រមទាំងលើកឡើងនូវអនុសាសន៍ដែលពាក់ព័ន្ធគម្រោង។